ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

លេខៈ ០៣១/១៨

# សេចក្តីណែនាំ
## ស្តីពី
## វិធានការបង្ការទប់ស្កាត់ហានិភ័យ នៃអំពើពពោះជំនួស

ដោយហេតុថា គោលការណ៍ណែនាំ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ ០៨៦/១៧ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៧ ស្តីពី (**បែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារកករណី នៃការពពោះជំនួស ដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស**) ត្រូវបញ្ចប់សុពលភាព នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ។

ដើម្បីទប់ស្កាត់ការកើតឡើងនូវករណីថ្មី នៃអំពើពពោះជំនួសដោយខុសច្បាប់ និងការពារមិនឲ្យកម្ពុជាក្លាយជាគោលដៅនៃអាជីវកម្មជួញដូរទារកតាមរូបភាពពពោះជំនួស គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សូមធ្វើការណែនាំដល់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ គប្បីអនុវត្តនូវវិធានការដូចខាងក្រោម៖

(១) បន្តសុពលភាព នៃគោលការណ៍ណែនាំ លេខ ០៨៦/១៧ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៧ ស្តីពី (**បែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារកករណី នៃការពពោះជំនួស ដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស**) ដើម្បីអនុវត្តចំពោះករណីទារកដែលបានកើត តាមរយៈការពពោះជំនួសក្នុងអំឡុងពេលមុនថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ។

(២) ហាមឃាត់ចំពោះករណីថ្មី នៃការពពោះជំនួស ដែលកើតឡើងក្រោយថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ដោយរឹតបន្តឹងវិធានការរដ្ឋបាល ការត្រួតពិនិត្យបច្ចេកវិទ្យាពាក់ព័ន្ធនឹងការពពោះតាមបណ្តាគ្លីនិក និងវិធានការច្បាប់ចំពោះបទល្មើសពាក់ព័ន្ធនានា រហូតដល់មានច្បាប់កំណត់ផ្សេងទៀត ។

(៣) បន្តស្រាវជ្រាវ តាមដាន ស៊ើបអង្កេតករណីសង្ស័យ រកអន្តរការី ឬជនដែលប្រើល្បិចឃុបឃិតអូសទាញឲ្យមានការពពោះជំនួស ការបោះបង់ទារក ការនាំទារកចេញដោយខុសច្បាប់ ការរត់ពន្ធ ការជួញដូរទារក ឬ អនីតិជន ដើម្បីផ្តន្ទាទោសតាមច្បាប់ដែលមានជាធរមាន ។

ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ គប្បីយកចិត្តទុកដាក់ផ្សព្វផ្សាយ និងអនុវត្តវិធានការនេះឲ្យមានប្រសិទ្ធភាព ចាប់ពីពេលចុះហត្ថលេខានេះតទៅ រហូតដល់មានបទប្បញ្ញត្តិថ្មីជាធរមាន ។

ថ្ងៃសុក្រ ៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ មីនា ឆ្នាំ២០១៨
**ប្រធានគណៈកម្មាធិការជាតិ**

**សម្តេចក្រឡាហោម ស ខេង**